**គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា**

المجلس الأعلى للشؤون الإسلامية في كمبوديا

HIGHEST COUNCIL FOR ISLAMIC RELIGIOUS AFFAIRS CAMBODIA

លេខៈ ០៩៩/២១ ចគជឥក...HICIRAC

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

ជាតិ សាសនា ព្រះមហាក្សត្រ

**NATION RELIGION KING**

ថ្ងៃ ចន្ទ ១៤ កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ជម្រាបជូន

## គណៈអ៊ីម៉ាំរាជធានី-ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ៖** ការត្រៀមស្មារតី និងសម្ភារៈចាំបាច់ដើម្បីរៀបចំបញ្ចុះសពសាសនិកឥស្លាមដែលស្លាប់ដោយសារជំងឺកូវីដ-១៩

**យោង ៖** ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា

- អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ស្តីពីការលើកលែងការបូជាសពសាសនិកឥស្លាម
- លិខិតលេខ១១៨/ ២១ក.ធ.ស ចុះថ្ងៃ ទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពី ការលើកលែងការបូជាសព សាសនិកឥស្លាមដែលស្លាប់ដោយសារជំងឺកូវីដ-១៩។

ន័យដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមរំលឹកថា ដោយសារព្រឹត្តិការណ៍២០ កុម្ភៈបានឆ្លងរាលដាលសឹងតែគ្រប់ខេត្ត ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ក្នុងនោះមានបងប្អូនសាសនិកឥស្លាមមួយចំនួនបានឆ្លងជំងឺកូវីដ-១៩ ពួកគាត់កំពុងព្យាបាលនៅតាមមន្ទីរពេទ្យនៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ពួកគាត់មួយចំនួនបាន និងកំពុងមានស្ថានភាពធ្ងន់ធ្ងរ។ ដូចនេះ ដើម្បីត្រៀមលក្ខណៈក្នុងការរៀបចំបញ្ចុះសពសាសនិកឥស្លាមដែលអាចនឹងមានស្លាប់ដោយសារជំងឺកូវីដ-១៩ នាពេលខាងមុខនេះ ក្រោយទទួលបានការកំណត់ទីតាំងសម្រាប់បញ្ចុះសព ខ្ញុំសូមឱ្យគណៈអ៊ីម៉ាំរាជធានី ខេត្ត ស្នើសុំការជួបពិភាក្សាជាមួយគណៈកម្មការ ឬក្រុមការងារបូជាសពថ្នាក់ខេត្តសាមីរបស់លោកអ៊ីម៉ាំដើម្បីសម្របសម្រួលយោបល់ដូចតទៅ៖

- តាមធម្មតា ការរៀបចំបញ្ចុះសពសាសនិកឥស្លាមមានលក្ខណៈសាមញ្ញបំផុតមិនចាំបាច់តម្រូវឱ្យប្រើមឈូសទេ ប្រើតែផ្ទាំងបន្ទះក្តាមួយផ្ទាំងជាការស្រេច ក៏ប៉ុន្តែក្នុងកាលៈទេសៈនេះ ដើម្បីងាយស្រួលក្នុងដឹកជញ្ជូនសពទៅកាន់ទីតាំងបញ្ចុះសពដែលនៅឆ្ងាយ និងជាវិធានបង្ការរបស់ក្រសួងសុខាភិបាលតម្រូវឱ្យមានការវេចខ្ចប់ត្រឹមត្រូវ។ សម្រាប់សពឥស្លាមអាចធ្វើជាបៀបហឹប ឬមឈូសដ៏សាមញ្ញ១ ជាលក្ខណៈឥស្លាមដោយមិនចាំបាច់មានចម្លាក់ជារូបភាពទេ ហើយក្រៅពីនេះមានដូចជាកាហ្វាន់(ក្រណាត់ស សម្រាប់រុំសព)។ល។ អាស្រ័យការសម្របសម្រួលរបស់គណៈអ៊ីម៉ាំរាជធានី-ខេត្ត។

ដើម្បីដំណើរការបានល្អ សូមលោកអ៊ីមាំចាត់ចែងឱ្យបានរួចរាល់ ដូចជាត្រៀមដីល្បាយខ្សាច់ស្អាតសម្រាប់ធ្វើការតៃមុំឱ្យម៉ាយិត ព្រមទាំងសម្ភារៈចាំបាច់ខ្លះដែលអាចត្រៀមទុកបានដែលក្រសួងសុខាភិបាលអនុញ្ញាតឱ្យប្រើប្រាស់។

សូមគណៈអ៊ីម៉ាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អ៊ីម៉ាំម៉ាស្ជិទ គ្រូបង្រៀនឥស្លាម និងសាសនិកឥស្លាម សហការអនុវត្តដោយស្មារតីទទួលខុសត្រូវ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។

**គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា**

**ប្រធាន**

**ឧកញ៉ា ស្មុះ - អាំរី**

**ចម្លងជូនៈ**

- ក្រសួងធម្មការ និងសាសនា
- ក្រសួងសុខាភិបាល

"ដើម្បីជូនជ្រាប"

- មន្ទីរធម្មការ និងសាសនា រាជធានី ខេត្ត
- គណៈកម្មការ ឬក្រុមការងារបូជាសពរាជធានី ខេត្ត

"ដើម្បីសហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

#144E, Road No 5, Krom 1, Phum 2, Chrang Chomreh 1, Russey Keo, Phnom Penh, Cambodia
Tel: (855) 23 23 04 87, H/P: (855) 11 827 486, E-mail: info@hicirac.org, Web: www.hicirac.org

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា

# គោលការណ៍ណែនាំ
# ស្តីពី
# ការរៀបចំសពដែលមានផ្ទុកមេរោគកូវីដ-១៩ នៅទីបញ្ចុះសពតាមទំនៀមទម្លាប់ ប្រពៃណី និងធម៌វិន័យសាសនាឥស្លាម តាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល

## ១. សេចក្តីផ្តើម

អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ស្តីពីការលើកលែងការបូជាសពសាសនិកឥស្លាម និងជនជាតិដើមភាគតិច ដែលបានស្លាប់ដោយសារជំងឺកូវីដ-១៩ សេចក្តីប្រកាសរបស់ក្រសួងធម្មការ និងសាសនា លេខ ១១៨/២១ ក.ធ.ស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីការលើកលែងការបូជាសពសាសនិកឥស្លាម និងជនជាតិដើមភាគតិចដែលបានស្លាប់ដោយសារជំងឺកូវីដ-១៩ សេចក្តីសម្រេចលេខ០៧៨ សនក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពផ្នែកសុខាភិបាល ទាក់ទងនឹងការគ្រប់គ្រងនិងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ក្នុងបរិបទនៃជំងឺរាតត្បាតកូវីដ-១៩ ក្នុងគោលបំណង៖ (១) រក្សាសុវត្ថិភាពក្នុងការគ្រប់គ្រងសពឲ្យបានសមស្របតាមបទដ្ឋានវេជ្ជសាស្ត្រ និងនិយាមវប្បធម៌ ប្រពៃណី សាសនា (២) បង្ការទប់ស្កាត់ការចម្លងនៃជំងឺកូវីដ-១៩ និងកាត់បន្ថយហានិភ័យសុខភាពសាធារណៈ ដោយអនុវត្តវិធានការសុខាភិបាល និងរក្សាបរិស្ថានអនាម័យល្អនៅមូលដ្ឋានសុខាភិបាល និងទីតាំងបញ្ចុះសព។

អនុលោមតាមគោលការណ៍ណែនាំ ក្រសួងសុខាភិបាល បានកំណត់នូវឧបករណ៍សម្ភារៈបច្ចេកទេសចាំបាច់ដែលត្រូវមានសម្រាប់ក្រុមមនុស្សដែលពាក់ព័ន្ធក្នុងការចូលរួមគ្រប់គ្រង និងចាត់ចែងសាកសព គោលការណ៍គ្រឹះនៃការគ្រប់គ្រងសព ព្រមទាំងសកម្មភាពសំខាន់ៗនៃការគ្រប់គ្រង និងចាត់ចែងសពផងដែរ។

ដើម្បីគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកជំងឺកូវីដ-១៩ ជាសាសនិកឥស្លាម អនុលោមតាមគោលការណ៍ណែនាំខាងលើ និងធានាបាននូវលក្ខណៈមនុស្សធម៌ សេចក្តីថ្លៃថ្នូរ ការគោរពនូវទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងធម៌វិន័យសាសនាឥស្លាមរបស់សាកសព និងក្រុមគ្រួសារសព គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដាក់ចេញនូវគោលការណ៍ណែនាំស្តីពី ការរៀបចំសពដែលមានផ្ទុកមេរោគកូវីដ-១៩ ជាសាសនិកឥស្លាម នៅទីបញ្ចុះសពតាមទំនៀមទម្លាប់ ប្រពៃណី និងធម៌វិន័យសាសនាឥស្លាមតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល ដែលមានខ្លឹមសារលម្អិតខាងក្រោម។

## ២. គោលការណ៍ និងសកម្មភាពអនុវត្តក្នុងការរៀបចំសពនៅទីតាំងបញ្ចុះសពរបស់បងប្អូនសាសនិកឥស្លាម

អនុលោមតាមគោលការណ៍គ្រឹះទាំងបីនៃការគ្រប់គ្រងសពអ្នកជំងឺកូវីដ-១៩ ដែលបានកំណត់៖ (១) សុវត្ថិភាពនៃការរៀបចំទុកដាក់សព (២) គោរពសេចក្ដីថ្លៃថ្នូររបស់សព និង (៣) បន្ថយហានិភ័យសុខភាពសាធារណៈ ក្រសួងសុខាភិបាលបានកំណត់នូវសកម្មភាពសំខាន់ៗពាក់ព័ន្ធនឹងលំហូរសកម្មភាពនៃការរៀបចំចាត់ចែងសពអ្នកជំងឺដោយចាប់ផ្ដើមពីការរៀបចំសពនៅក្នុងបន្ទប់អ្នកជំងឺនៅមន្ទីរពេទ្យ ដោយគ្រូពេទ្យ និងបុគ្គលិក ការរៀបចំទុកដាក់សពនៅបន្ទប់រក្សាសពដោយបុគ្គលិក បន្ទប់រក្សាសព ការចាត់ចែងដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យដោយក្រុមដឹកជញ្ជូន ការរៀបចំសពនៅទីតាំងបញ្ចុះសពដោយអ្នកយល់ដឹងសាសនា ក្នុងការបញ្ចុះសពឥស្លាមអាចជាគ្រូពេទ្យឥស្លាមស្រាប់ ឬជាគ្រួសារនៃសព និងក្រុមអ្នកសម្អាតបរិស្ថានជាដើម។

ក្នុងន័យនេះ សម្រាប់សពអ្នកជំងឺកូវីដ-១៩ ជាសាសនិកឥស្លាម គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា សូមកំណត់នូវគោលការណ៍ និងសកម្មភាពអនុវត្តនានានៅក្នុងដំណាក់កាលនៃការរៀបចំសពនៅទីតាំងបញ្ចុះសពរបស់បងប្អូនសាសនិកឥស្លាមដោយមានការចូលរួមរបស់ក្រុមអ្នកបញ្ចុះសព (អ្នកធ្វើតៃម៉ុំ អ្នកថ្វាយបង្គំសឡាតម៉ៃយិត អ្នកបញ្ចុះសព) និងក្រុមគ្រួសារសពដូចតទៅ៖

### ២.១. ទីតាំងបញ្ចុះសព

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំដីចំនួន ០៥ ហិកតា ស្ថិតក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សម្រាប់ជាទីបញ្ចុះសពមូស្លីម ដែលស្លាប់ដោយសារជំងឺកូវីដ-១៩។

ចំពោះសពអ្នកជំងឺកូវីដ-១៩ នៅតាមបណ្ដាខេត្ត ក្រុង ស្រុកនានា ត្រូវប្រញាប់បញ្ចុះនៅទីតាំងដែលអាជ្ញាធរថ្នាក់ខេត្ត មន្ទីរ ឬមន្ត្រីសុខាភិបាល និងគណៈអ៊ីម៉ាំខេត្ត បានឯកភាព សម្រេច និងកំណត់រួចរាល់។

### ២.២. ដំណើរការរៀបចំបញ្ចុះសព

បន្ទាប់ពីសពអ្នកជំងឺកូវីដ-១៩ ដែលមានលិខិតបញ្ជាក់ និង/ឬមានការទទួលស្គាល់ និង/ឬកំណត់អត្តសញ្ញាណជាមុស្លិម ត្រូវបានដឹកជញ្ជូនមកដល់ទីតាំងបញ្ចុះសពហើយ ពិធីបញ្ចុះសពត្រូវធ្វើឡើងតាមទំនៀមទម្លាប់ ប្រពៃណី ជំនឿ ធម៌វិន័យសាសនាឥស្លាម ក្រោមការចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយមានការកំណត់ចំនួនមនុស្សចូលរួមក្នុងកម្រិតអប្បបរមា ដោយរក្សាគម្លាតសុវត្ថិភាពសង្គម និងបុគ្គល។ ក្នុងពិធីបញ្ចុះសព គ្រួសារ/ញាតិមិត្តរបស់សព អ្នកធ្វើតៃម៉ុំ និងអ្នកថ្វាយបង្គំសឡាត ក្រុមអ្នកបញ្ចុះសព គប្បីអនុវត្តតាមវិធានការណែនាំខាងក្រោម៖

**ក្រុមអ្នកចូលរួមបញ្ចុះសព**

អ្នកធ្វើតៃម៉ុំ អ្នកថ្វាយបង្គំសឡាតម៉ៃយិត និងក្រុមបញ្ចុះសព អាចប្រឈមនឹងហានិភ័យនៃការចម្លងកូវីដ-១៩។ ដើម្បីសុវត្ថិភាពក្នុងការលើកដាក់សពធ្វើការតៃម៉ុំ អនុវត្តសឡាតម៉ៃយិត (ថ្វាយបង្គំជូនដំណើរសព) និងលើកដាក់សពបញ្ចុះក្នុងរណ្ដៅនៅលើទីតាំងបញ្ចុះសព អ្នកចូលរួមបញ្ចុះសពត្រូវពាក់ឧបករណ៍ការពារខ្លួនឲ្យបានត្រឹមត្រូវ ហើយលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាតភ្លាមៗ។

| វិធានការត្រូវអនុវត្ត | | |
|---|---|---|
| ១ | លាងដៃឲ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូ ឬទឹកសម្លាប់មេរោគ មុននិងក្រោយពេលលើកទុកដាក់សព។ | √ |
| ២ | ប្រើប្រាស់ឧបករណ៍ការពារខ្លួនឲ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាសពេទ្យធម្មតា (Surgical Mask) ស្រោមដៃ អាវពេទ្យ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីខ្លួនសាកសព ត្រូវពាក់បាំងមុខ ឬវ៉ែនតាការពារ និងអាវអៀមមិនជ្រាបទឹកបន្ថែមទៀត។ | √ |
| ៣ | បន្ថយការលើកទុកដាក់សាកសព ចុះឡើងឲ្យនៅតិចបំផុត។ | √ |
| ៤ | លាងសម្អាតរថយន្ត ឬមធ្យោបាយដឹកជញ្ជូនទាំងផ្នែកខាងក្នុង និងខាងក្រៅ ដោយប្រើទឹកសម្លាប់មេរោគនៅក្រោយពេលដឹកជញ្ជូនរួចម្ដងៗ។ | √ |

HICIRAC COUNCIL FOR ISLAMIC RELIGIOUS AFFAIRS CAMBODIA

**ការធ្វើតៃមុំ**

សម្ភារៈសម្រាប់ធ្វើតៃមុំ រួមមាន៖

- ក្រដាស់វ៉ាម A4 មួយចំនួន ឬក្រណាត់ពណ៌ស ដើម្បីក្រាលដាក់ធូលីដី(ដីល្បាយខ្សាច់) សម្រាប់តៃមុំ
- ធូលីដីស្អាត (ក្នុងបរិមាណសមល្មម និងគ្រប់គ្រាន់)។

**ចំនួនអ្នកធ្វើតៃមុំ គោលការណ៍ និងរបៀបរបបធ្វើតៃមុំ**

អ្នកទទួលបន្ទុកធ្វើតៃមុំ កម្រិតត្រឹមតែមួយរូប ដែលត្រូវមានវូទុ មានសម្លៀកបំពាក់ឧបករណ៍ការពារខ្លួនដូចបានបញ្ជាក់ខាងលើ ហើយចេះពីរបៀបធ្វើតៃមុំ។

អ្នកធ្វើតៃមុំត្រូវអនុវត្តដូចតទៅ៖

## ៣. ខ្លឹមសារធម៌វិន័យសំខាន់ៗនៃការធ្វើតៃមុំ និងសម្អាតម៉ៃយិត

### ៣.១. រ៉ូគុនតៃមុំឲ្យសាកសពមាន៖

**- នៀត**

نَوَيْتُ التَّيَمُّمَ عَلَى هَذَا الْمَيِّتِ / هَذِهِ الْمَيِّتَةِ لِلّٰهِ تَعَالَى

ខ្ញុំតៃមុំឲ្យម៉ៃយិតនេះ កាវ៉ាណាអល់ឡោះ

**- ផ្តិតបាតដៃលើធូលីដី លើកទី១**

សម្រាប់ជូតផ្ទៃមុខសាកសព

**- ផ្តិតបាតដៃលើធូលីដី លើកទី២**

សម្រាប់ជូតដៃសាកសពទាំងសងខាង ពីចុងម្រាមដៃ ដល់កែងដៃ

**- ឌូអា (ស៊ូណាត់សូត្រឌូអា)**

اَشْهَدُ اَنْ لَااِلٰهَ اِلَّااللهُ وَحْدَهُ لَاشَرِيْكَ لَهُ وَاَشْهَدُ اَنَّ مُحَمَّدًاعَبْدُهُ وَرَسُوْلُهُ

اَللّٰهُمَّ اجْعَلْنِيْ مِنَ التَّوَّابِيْنَ وَاجْعَلْنِيْ مِنَ الْمُتَطَهِّرِيْنَ، وَجْعَلْنِيْ مِنْ عِبَادِكَ الصَّالِحِيْنَ

**- តើរតើប (តាមលំដាប់លំដោយ)។**

ដីល្បាយខ្សាច់ត្រូវបានរៀបចំជាស្រេច



**របៀបអនុវត្ត**

ទះដីថ្នមៗលើកទី១



យកដីជាប់នឹងដៃមកជូតមុខ



យកដៃទះដីថ្នមៗ លើកទី២



យកបាតដៃដែលជាប់ដីលើដៃឆ្វេងទៅជូតឲ្យដៃស្តាំ



យកបាតដៃដែលជាប់ដីលើដៃស្តាំទៅជូតឲ្យដៃឆ្វេង



**គោលការណ៍ និងរបៀបរបបសឡាតម៉ៃយិត (ថ្វាយបង្គំជូនដំណើរសព) និងចំនួនអ្នកចូលរួម**

ការធ្វើសឡាតម៉ៃយិត ត្រូវអនុវត្តនៅជិតទីកន្លែងបញ្ចុះសពនៃទីតាំងបញ្ចុះសព ដែលបញ្ជាក់ខាងលើ។ ចំនួនអ្នកថ្វាយបង្គំជីណាហ្សះត្រូវកំណត់ចំនួន ៤ (បួន) រូបតែប៉ុណ្ណោះ (ដោយមិនរាប់បញ្ចូលអ្នកធ្វើតែម៉ាំ)។ អ្នកថ្វាយបង្គំ ត្រូវរក្សាគម្លាតសុវត្ថិភាពចម្ងាយ ១ម៉ែត្រកន្លះ រវាងអ៊ីម៉ាំ និងសព និងរវាងអ្នកចូលរួមថ្វាយបង្គំ។ សូមបញ្ជាក់ថាក្រុមគ្រួសារ/ញាតិមិត្តអាចចូលរួមសឡាតម៉ៃយិត ឆ្ងាយពីកន្លែងបញ្ចុះសព (អាចនៅក្រៅបរិវេណទីកន្លែងបញ្ចុះសព)។

ចំពោះការវេចខ្ចប់សពអាចធ្វើជារបៀបហឹប ឬមឈូសលក្ខណៈឥស្លាម (គ្មានចម្លាក់ឬរូបភាពផ្សេងៗ) ឬយ៉ាងណានោះអាស្រ័យគណៈអ៊ីម៉ាំរាជធានី-ខេត្ត សម្របសម្រួលជាមួយក្រុមការងារ ឬគណៈកម្មការបូជាសពនៅតាមខេត្តសាមីដើម្បីកំណត់។

**សឡាតម៉ៃយិតបុរស និងស្ត្រី មានដូចតទៅ:**




គម្លាតសុវត្ថិភាពរវាងអ៊ីមាំ និង ម៉ាក់មុម យ៉ាងតិច ១ ម៉ែត្រកន្លះ (1.5m)

### ៣.២. រូ៊កុនសឡាតម៉ៃយិតមាន៖

១- នៀត
២- ឈរត្រង់ខ្លួន
៣- តឹកពៀរបួនដង
៤- លើកដៃតឹកពៀរ
៥- សូត្រ ហ្វាទីហះ
៦- សូត្រសឡាវ៉ាត
៧- សូត្រទូអាឲ្យសាកសព(ម៉ៃយិត)
៨- ឲ្យសាឡាម។

### ៣.៣. ការនៀតសឡាតម៉ៃយិត

**-នៀតសឡាតម៉ៃយិត(សព)ប្រុស**

أُصَلِّى عَلَى هَذَاالْمَيِّتِ اَرْبَعَ تَكْبِرَاتٍ فَرْضَ الْكِفَايَةِ إِمَاماً / مَأْمُوْمًا لِلّٰهِ تَعَالَى

ខ្ញុំសឡាតលើម៉ៃយិតប្រុសនេះ ៤តឹកពៀរ ជាអ៊ីម៉ាំ /ម៉ាក់មុម កាវ៉ាណាអល់ឡោះ

**-នៀតសឡាតម៉ៃយិត(សព)ស្ត្រី**

أُصَلِّى عَلَى هَذِهِ الْمَيِّتَةِ اَرْبَعَ تَكْبِرَاتٍ فَرْضَ الْكِفَايَةِ إِمَاماً / مَأْمُوْمًا لِلّٰهِ تَعَالَى

ខ្ញុំសឡាតលើម៉ៃយិតស្រីនេះ ៤តឹកពៀរ ជាអ៊ីម៉ាំ /ម៉ាក់មុម កាវ៉ាណាអល់ឡោះ

**-នៀតសឡាតម៉ៃយិត(សព) ពីរនាក់**

أُصَلِّى عَلَى هَذَيْنِ الْمَيِّتَيْنِ اَرْبَعَ تَكْبِرَاتٍ فَرْضَ الْكِفَايَةِ إِمَاماً / مَأْمُوْمًا لِلّٰهِ تَعَالَى

ខ្ញុំសឡាតលើម៉ៃយិតពីរនាក់នេះ ៤តឹកពៀរ ជាអ៊ីម៉ាំ /ម៉ាក់មុម កាវ៉ាណាអល់ឡោះ

**-នៀតសឡាតម៉ៃយិត(សព) ដែលមានគ្នាច្រើន**

أُصَلِّى عَلَى هَذِهِ الْأَمْوَاتِ اَرْبَعَ تَكْبِرَاتٍ فَرْضَ الْكِفَايَةِ إِمَاماً / مَأْمُوْمًا لِلّٰهِ تَعَالَى

ខ្ញុំសឡាតលើម៉ៃយិតទាំងអស់នេះ ៤តឹកពៀរ ជាអ៊ីម៉ាំ /ម៉ាក់មុម កាវ៉ាណាអល់ឡោះ

## ៣.៤. សឡាតម៉ៃយិត ហ្វារទូគីហ្វាយ៉ះ(មិនអាចលើកលែងបាន) មាន៤ តឹកពៀរ៖

១- តឹកពៀរទី១ (ជាមួយនៀត) រួច សូត្រហ្វាទីហះ មួយចប់

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ، أَلْحَمْدُ للهِ رَبِّ الْعَالَمِيْنَ

២- តឹកពៀរទី២ រួច សូត្រសឡាវ៉ាតលើណាពី

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَعَلٰى آلِ مُحَمَّدٍ

៣- តឹកពៀរទី៣ រួច សូត្រទូអា

اَللّٰهُمَّ اغْفِرْ لَهُ (ها) وَارْحَمْهُ (ها)

៤- តឹកពៀរទី៤ រួច ឲ្យសាឡាមតែម្តង ឬសូណាត់សូត្រ

اَللّٰهُمَّ لاَ تَحْرِمْنَا أَجْرَهُ (ها) وَلاَ تَفْتِنَّا بَعْدَهُ (ها)

### បន្ទាប់ពីសឡាតម៉ៃយិតរួច ស៊ូណាត់សូត្រទូអា

**សូត្រទូអាឲ្យម៉ៃយិតប្រុស**

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

اَلْحَمْدُلِلّٰه رَبِّ الْعَالَمِيْنَ، وَالصَّلاَةُ وَالسَّلاَمُ عَلَى سَيِّدِنَا مُحَمَّدٍ أَشْرَفِ الْمُرْسَلِيْنَ وَعَلَى آلِهِ وَصَحْبِهِ أَجْمَعِيْنَ.

اَللّٰهُمَّ اجْعَلْ قَبْرَهُ رَوْضَةً مِنْ رِيَاضِ الْجَنَّةِ اَللّٰهُمَّ أَنْتَ رَبُّهُ وَأَنْتَ خَلَقْتَهُ، وَأَنْتَ هَدَيْتَهُ لِلْإِسْلَامِ. وَأَنْتَ قَبَضْتَ رُوْحَهُ وَأَنْتَ أَعْلَمُ بِسِرِّهِ وَعَلَانِيَّتِهِ، وَقَدْ جِئْنَاكَ رَاغِبِيْنَ شُفَعَاءَ لَهُ فَاغْفِرْلَنَا، وَلَهُ بِرَحْمَتِكَ يَا أَرْحَمَ الرَّاحِمِيْنَ ، وَصَلَّى اللّٰهُ عَلَى سَيِّدِنَا مُحَمَّدٍ وَعَلَى آلِهِ وَصَحْبِهِ وَسَلَّمَ وَالْحَمْدُلِلّٰهِ رَبِّ الْعَلَمِيْنَ.

**សូត្រទូអាឲ្យម៉ៃយិតស្ត្រី**

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

اَلْحَمْدُلِله رَبِّ الْعَالَمِيْنَ، وَالصَّلاَةُ وَالسَّلاَمُ عَلى سَيِّدِنَا مُحَمَّدٍ أَشْرَفِ الْمُرْسَلِيْنَ وَعَلَى آلِهِ وَصَحْبِهِ اَجْمَعِيْنَ. اَللّٰهُمَّ اجْعَلْ قَبْرَهَا رَوْضَةً مِنْ رِيَاضِ الْجَنَّةِ اَللّٰهُمَّ أَنْتَ رَبَّهَا وَأَنْتَ خَلَقْتَهَا، وَأَنْتَ هَدَيْتَهَا لِلْإِسْلَامِ، وَأَنْتَ قَبَضْتَ رُوْحَهَا وَأَنْتَ أَعْلَمُ بِسِرِّهَا وَعَلَانِيَّتِهَا، وَقَدْ جِئْنَاكَ رَاغِبِيْنَ شُفَعَاءَ لَهَا فَاغْفِرْلَنَا وَلَهَا بِرَحْمَتِكَ يَا أَرْحَمَ الرَّحِمِيْنَ. وَصَلَّى اللّٰهُ عَلَى سَيِّدِنَا مُحَمَّدٍ وَعَلَى آلِهِ وَصَحْبِهِ وَسَلَّمَ وَالْحَمْدُلِلّٰهِ رَبِّ الْعَالَمِيْنَ.

### ការបញ្ចុះសពនៅក្នុងរណ្តៅ (គូពួគរ៍)

ក្រុមអ្នកបញ្ចុះសព និងគ្រួសារ/ញាតិមិត្តដែលមានចំនួន ៤ នាក់ ដែលអ្នកទាំងនោះមិនមែនជាអ្នកប៉ះពាល់ផ្ទាល់នឹងសពដែលមានផ្ទុកជំងឺកូវីដ-១៩ ឬជាអ្នកស្ថិតនៅក្នុងការសង្ស័យថាមានផ្ទុកជំងឺកូវីដ-១៩ ឬជាអ្នកដែលផ្ទុកកូវីដ-១៩ ឡើយ។

បន្ទាប់ពីការអនុវត្តសឡាតម៉ៃយិតរួចរាល់ សាកសពដែលបានរៀបចំដាក់ក្នុងមឈូស ត្រូវទម្លាក់ចូលទៅក្នុងរណ្តៅដីដែលត្រូវបានជីកហើយ ដោយមនុស្ស ៤ នាក់ ជាអ្នកសម្រូតសពចូលទៅក្នុងរណ្តៅ រួចហើយកាយដីកប់ធ្វើជាផ្នូរតាមទំនៀមទម្លាប់របស់សាសនិកឥស្លាម ដោយមានការបញ្ចប់ជាមួយនឹងការសូត្រធម៌ទូអាឲ្យសពតាមរបៀបសង្ខេបខ្លីបំផុត។

وَاللّٰهُ أَعْلَمُ